THE COMMONWEALTH OF MASSACHUSETTS
EXECUTIVE OFFICE OF LABOR AND WORKFORCE DEVELOPMENT
DEPARTMENT OF INDUSTRIAL ACCIDENTS

ខុមុំនវែលម៉ាស្សាឈូសិត
ការិយាល័យប្រតិបត្តិការងារ និងអភិវឌ្ឍន៍ពលករ
ក្រសួងគ្រប់គ្រងគ្រោះថ្នាក់ឧស្សាហកម្ម

# គោលការណ៍ណែនាំនិយោជិករងរបួស អំពីសំណងនិយោជិករដ្ឋម៉ាស្សាឈូសិត

Esta guía está disponible en español en nuestro sitio electrónico: **www.mass.gov/dia**

Este Guia está disponível em português no nosso site: **www.mass.gov/dia**

Es manual sta skritu na Kriolu di Kabu Verdi prontu pa bu uzu na *website* (pagina na interneti): **www.mass.gov/dia**

本指南的中文版位於我們的網址:
**www.mass.gov/dia**

Có Hướng Dẫn này bằng tiếng Việt Nam tại mạng lưới của chúng tôi: **www.mass.gov/dia**

W ap jwenn gid sa a ekri nan lang kreyòl sou sit entènèt nou an : **www.mass.gov/dia**

គោលការណ៍ណែនាំនេះ
អាចមានជាភាសាខ្មែរនៅលើវេបសាយរបស់យើង :
**www.mass.gov/dia**

يتوفر هذا الدليل باللغة العربية على موقعنا التالي على الويب:
**www.mass.gov/dia**



## តើសំណងនិយោជិកគឺជាអ្វី?

ប្រព័ន្ធសំណងនិយោជិករដ្ឋម៉ាស្សាឈូសិត កើតមានឡើងដើម្បីធ្វើឱ្យប្រាកដថានិយោជិកត្រូវបានការពារដោយការធានារ៉ាប់រង ប្រសិនបើពួកគេរងរបួសនៅពេលធ្វើការងារ ឬមានជម្ងឺពាក់ព័ន្ធការងារ ។

ដោយស្ថិតក្រោមប្រព័ន្ធនេះ **និយោជកទាំងអស់ត្រូវបានតម្រូវឱ្យផ្តល់ការរ៉ាប់រងនៃការធានារ៉ាប់រងសំណងនិយោជិក (Workers' Compensation - WC) ដល់និយោជិករបស់ខ្លួនទាំងអស់** តាមរយៈច្បាប់ទូទៅរដ្ឋម៉ាស្សាឈូសិត (Massachusetts General Laws) ជំពូក 152 សេកសិន 25A ។ ការធានារ៉ាប់រងនេះ បង់ប្រាក់សំរាប់ការព្យាបាលវេជ្ជសាស្ត្រសមរម្យ និងចាំបាច់ណាមួយពាក់ព័ន្ធនឹងការ រងរបួស ឬជម្ងឺពាក់ព័ន្ធនឹងការងារ បង់សំណងសំរាប់ការបាត់បង់ប្រាក់កម្រៃបន្ទាប់ពីប្រាំថ្ងៃដំបូងនៃពិការភាពទាំងស្រុង ឬមិនពេញលេញ ហើយនៅក្នុងករណីមួយចំនួនផ្តល់ជូនការបណ្តុះបណ្តាលឡើងវិញសំរាប់និយោជិកដែលមានលក្ខណៈសម្បត្តិទទួល ។

ក្រសួងគ្រប់គ្រងគ្រោះថ្នាក់ឧស្សាហកម្ម (Department of Industrial Accidents - DIA) គឺជាភ្នាក់ងារដែលទទួលខុសត្រូវគ្រប់គ្រងច្បាប់ស្តីពីសំណងនិយោជិកនៅក្នុងរដ្ឋម៉ាស្សាឈូសិត ។

## អ្វីដែលយើងខ្ញុំអនុវត្ត

DIA គឺជាប្រព័ន្ធតុលាការចម្បងដែលទទួលខុសត្រូវចំពោះការដោះស្រាយជម្លោះបណ្តឹងទាមទារនៃសំណងនិយោជិក ។ បុគ្គលិកនៃព័ត៌មាន សាធារណៈ (Public Information) របស់យើងខ្ញុំ អាចឆ្លើយសំណួររបស់អ្នកអំពីអត្ថប្រយោជន៍នៃសំណងនិយោជិក និងឱ្យអ្នកដឹងអំពីនីតិវិធី ត្រឹមត្រូវដើម្បីអនុវត្តតាមក្នុងការទទួលបានអត្ថប្រយោជន៍ទាំងនេះ ។ ប្រសិនបើបណ្តឹងទាមទារនៃការរងរបួស ឬជម្ងឺរបស់អ្នក ត្រូវបានបដិសេធ ដោយក្រុមហ៊ុនធានារ៉ាប់រង ឬប្រសិនបើអ្នកមិនទទួលបានអត្ថប្រយោជន៍ទាំងអស់ដែលអ្នកគិតថាអ្នកមានសិទ្ធិទទួល បុគ្គលិកនៃព័ត៌មានសាធារណៈ (Public Information) របស់ DIA អាចមានបម្រើជូនដើម្បីជួយណែនាំអ្នកនូវដំណើរការទាំងមូលបាន ។

វាគឺជាការសំខាន់ដែលអ្នកត្រូវរក្សាទុកឯកសារណាមួយ ដែលនិយោជកររបស់អ្នក ឬក្រុមហ៊ុនធានារ៉ាប់រងរបស់និយោជិកផ្ញើរជូនអ្នក ក៏ដូចជាសំណៅចម្លងនៃទម្រង់ណាមួយដែលពួកគេឱ្យអ្នកបំពេញឱ្យពួកគេ ។ ប្រសិនបើអ្នកទូរស័ព្ទទៅការិយាល័យព័ត៌មានសាធារណៈ (Public Information Office) របស់យើងខ្ញុំ សូមមានទម្រង់ទាំងនេះជាមួយ រួមនឹងប៊ិច ឬខ្មៅដៃ ព្រមទាំងក្រដាសកត់ត្រា ។ វាប្រហែលអាចមានសារៈប្រយោជន៍ក្នុងការសរសេរសំណួររបស់អ្នកជាមុន អាស្រ័យហេតុនេះអ្នកមិនភ្លេចសួរសំណួរណាមួយដែលអ្នកអាចមាន ។

ខិតប័ណ្ណនេះ គឺជាទិដ្ឋភាពទូទៅនៃដំណើរការដើម្បីអនុវត្តតាម ប្រសិនបើអ្នកមានការរងរបួស ឬជម្ងឺពាក់ព័ន្ធនឹងការងារ ។ ការណែនាំនេះផ្តល់ជូនព័ត៌មានអំពី**ការទទួលខុសត្រូវរបស់អ្នក** និងការទទួលខុសត្រូវទាំងឡាយរបស់**និយោជកររបស់អ្នក** និង**ក្រុមហ៊ុនធានារ៉ាប់រងនិយោជក របស់អ្នក ។** ការណែនាំនេះ នឹងពន្យល់ពីដំណើរការនៃជម្លោះនៃសំណងនិយោជក និងអត្ថប្រយោជន៍ដែលអាចមានរួមទាំងការទូទាត់ការបង់ប្រាក់ សរុបផ្តាច់ និងសេវាកម្មស្តារនីតិសម្បទាវិជ្ជាជីវៈ ។ សំណួរសួរញឹកញាប់ជាច្រើន អាចត្រូវបានរកឃើញនៅលើគេហទំព័ររបស់យើងខ្ញុំតាម [www.mass.gov/dia](http://www.mass.gov/dia) ។

សូមជ្រាបថា ព័ត៌មានដែលមាននៅក្នុងខិតប័ណ្ណនេះ គឺមានលក្ខណៈទូទៅ និងមិនមានបំណងជំនួសការប្រឹក្សាផ្នែកច្បាប់ឡើយ ។ ការផ្លាស់ប្តូរនៅក្នុងច្បាប់ ឬដំណើរការពិតជាក់លាក់អំពីសំណុំរឿងរបស់អ្នក អាចបណ្តាលឱ្យមានការបកស្រាយផ្នែកច្បាប់ ដែលមានភាពខុសគ្នាពីអ្វី ដែលត្រូវបានបង្ហាញនៅទីនេះ ។

## តើអ្នកត្រូវការមេធាវីដែរទេ?

ពាក់កណ្តាលនៃបណ្តឹងទាមទាររបស់និយោជិកដែលរងរបួស មិនត្រូវបានបដិសេធដោយក្រុមហ៊ុនធានារ៉ាប់រង ឬនិយោជក ។ ប្រសិនបើបណ្តឹងទាមទាររបស់អ្នក ត្រូវបានបដិសេធ **សូមជ្រាបច្បាស់ថា អ្នកត្រូវស្វែងរកការប្រឹក្សាផ្នែកច្បាប់** ដើម្បីការពារសិទ្ធិ និងអត្ថប្រយោជន៍របស់អ្នក ដោយសារតែភាពស៊ាំញ៉ាំនៃច្បាប់ស្តីពីសំណងនិយោជិក ។ ច្បាប់ចែងថា ក្រុមហ៊ុនធានារ៉ាប់រងត្រូវបង់ប្រាក់កម្រៃមេធាវី ប្រសិនបើអ្នកឈ្នះសំណុំរឿងរបស់អ្នក ។ នៅក្នុងករណីមួយចំនួន ក្រុមហ៊ុនធានារ៉ាប់រង អាចកាត់បន្ថយការបង់ប្រាក់របស់អ្នកដើម្បីជួយបង់ប្រាក់ថ្លៃមេធាវីរបស់អ្នក ។ ប្រសិនបើ អ្នកចាញ់ មេធាវីអាចយកថ្លៃពីអ្នកត្រឹមត្រការចំណាយជាក់លាក់បន្តិចបន្តួចប៉ុណ្ណោះ អ្នកមិនចាំបាច់ *ត្រូវការ*មេធាវីដើម្បីដាក់បណ្តឹងទាមទារឡើយ ហើយអ្នកអាចតំណាងឱ្យខ្លួនអ្នកផ្ទាល់សំរាប់ដំណើរការបណ្តឹងណាមួយនៅចំពោះមុខ DIA ។ នេះគឺត្រូវបានផ្តល់ជាយោបល់នៅក្នុងករណីភាគច្រើន បំផុត ។

**និយោជិករបស់ DIA មិនត្រូវបានអនុញ្ញាតធ្វើការបញ្ជូនទៅកាន់មេធាវីឡើយ ។** សមាគមមេធាវីប្រចាំរដ្ឋម៉ាសូឈូសិត (Massachusetts Bar Association) អាចបញ្ជូនអ្នកទៅកាន់មេធាវីដែលដោះស្រាយសំណុំរឿងពាក់ព័ន្ធសំណងនិយោជិក ។ ដើម្បីទទួលបានសេវាកម្មបញ្ជូនទៅកាន់មេធាវីរបស់សមាគមមេធាវីប្រចាំរដ្ឋម៉ាសូឈូសិត សូមទូរស័ព្ទទៅលេខ (617) 654-0400 នៅក្នុងតំបន់បូស្តុន ឬលេខឥតគិតថ្លៃតាមលេខ (866) 627-7577 ឬចូលមើល www.massbar.org និងចុចលើបន្ទះ "**Need a Lawyer?**" ។

## តើមានអ្វីកើតឡើងនៅពេលដែលអ្នកមានការរងរបួស ឬជម្ងឺពាក់ព័ន្ធនឹងការងារ?

ប្រសិនបើអ្នកមានការរងរបួស ឬជម្ងឺពាក់ព័ន្ធនឹងការងារ ដែលបណ្តាលមកពីការបាត់បង់ពេលវេលាធ្វើការយ៉ាងហោចណាស់ប្រាំថ្ងៃពេញ ឬមិន ពេញលេញ និយោជករបស់អ្នកត្រូវដាក់ជូន *របាយការណ៍លើកដំបូងរបស់និយោជកអំពីការរងរបួស ឬការស្លាប់ (Employer's First Report of Injury or Fatality) [ទម្រង់ 101]* ។ មួយច្បាប់ត្រូវបានដាក់ជូន DIA ច្បាប់ទីពីរដាក់ជូនក្រុមហ៊ុនធានារ៉ាប់រងនៃសំណង និយោជិករបស់និយោជក និងច្បាប់ទីបីត្រូវបានផ្តល់ជូនអ្នក ។ *ទម្រង់ 101* ត្រូវតែបានដាក់ជូននៅក្នុងអំឡុងប្រាំពីរថ្ងៃ (មិនរួមបញ្ចូលថ្ងៃអាទិត្យ និងថ្ងៃបុណ្យជាតិតាមច្បាប់) បន្ទាប់ពីថ្ងៃទីប្រាំនៃការបាត់បង់ពេលវេលាដោយសារការរងរបួស ឬជម្ងឺ ។ នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងទទួល បានទម្រង់ពីនិយោជករបស់អ្នក ពួកគេមានពេលវេលា 14 ថ្ងៃដើម្បីស៊ើបអង្កេតបណ្តឹងទាមទារ និងកំណត់ថាតើត្រូវបង់ប្រាក់ចំពោះបណ្តឹងទាមទារ ឬអត់ ។

**សំខាន់ :** ប្រសិនបើនិយោជករបស់អ្នក មិនផ្ញើរជូន*ទម្រង់101* ជូនក្រុមហ៊ុនធានារ៉ាប់រងអំឡុង 30 ថ្ងៃនៃការរងរបួសរបស់អ្នក សូមរាយការណ៍អំពីការរងរបួសជាលាយលក្ខណ៍អក្សរទៅកាន់ក្រុមហ៊ុនធានារ៉ាប់រងដោយខ្លួនអ្នកផ្ទាល់ ឬបំពេញ*បណ្តឹងទាមទាររបស់និយោជក (Employee's Claim) [ទម្រង់110]* របស់ DIA និងផ្ញើរជូនក្រុមហ៊ុនធានារ៉ាប់រងនូវទម្រង់បំពេញរួចមួយច្បាប់ ។ អ្នកអាចប្រើប្រាស់ បំពេញ និងព្រីនទម្រង់នៅក្នុងផ្នែក Forms and Publications តាមរយៈ [www.mass.gov/dia](http://www.mass.gov/dia) ។

**និយោជករបស់អ្នក ត្រូវបានតម្រូវឱ្យមានប័ណ្ណផ្សព្វផ្សាយបង្ហាញនៅកន្លែងធ្វើការ ដោយមានឈ្មោះ និងអាសយដ្ឋានរបស់ក្រុមហ៊ុនធានារ៉ាប់រងនៃសំណងនិយោជិករបស់ខ្លួន ព្រមទាំងព័ត៌មានស្តីពីគោលការណ៍ ។** ប្រសិនបើនិយោជករបស់អ្នក មិនមានប័ណ្ណផ្សព្វផ្សាយនេះបង្ហាញ ហើយនឹងមិនប្រាប់អ្នកអំពីឈ្មោះក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួន ការិយាល័យធានារ៉ាប់រង (Office of Insurance) របស់ DIA (617-626-5480/ 617-626-5481, នឹងព្យាយាមជួយអ្នក ។ ប្រសិនបើអ្នកសង្ស័យថា និយោជករបស់អ្នក មិនមានការធានា រ៉ាប់រង សូមទូរស័ព្ទទៅការិយាល័យស៊ើបអង្កេត (Office of Investigations) របស់យើងខ្ញុំតាមលេខហៅបន្ត 617-727-4900 ext.7406 ។

## តើមានអ្វីកើតឡើងនៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងសម្រេចបង់ប្រាក់បណ្តឹងទាមទារ?

ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងព្រមព្រៀងបង់ប្រាក់បណ្តឹងទាមទារ ពួកគេនឹងផ្ញើរជូនអ្នកនូវ *សេចក្តីជូនដំណឹងអំពីការបង់ប្រាក់របស់ក្រុមហ៊ុនធានា រ៉ាប់រង (Insurer's Notification of Payment) [ទម្រង់ 103]* ។

### តើអត្ថប្រយោជន៍ ឬមូលប្បទានប័ត្រនឹងចាប់ផ្តើមនៅពេលណា?

អ្នកគួរតែចាប់ផ្តើមទទួលបានមូលប្បទានប័ត្រអំឡុងបីទៅបួនសប្តាហ៍ បន្ទាប់ពីការរងរបួស ឬជម្ងឺរបស់អ្នក ។ អ្នកនឹងទទួលបានសំណងសំរាប់ការបាត់បង់ប្រាក់កម្រៃចំពោះថ្ងៃណាមួយដែលអ្នកមិនអាចធ្វើការងារបាន បន្ទាប់ពីប្រាំថ្ងៃពេញ ឬមិនពេញលេញដំបូង ។ អ្នកមិនត្រូវបានផ្តល់សំណងសំរាប់ប្រាំថ្ងៃដំបូងនៃអសមត្ថភាព បើពុំនោះទេលុះត្រាតែអ្នកពិការចាប់ 21 ថ្ងៃឬច្រើនជាងនេះ ។

រយៈពេល 180 ថ្ងៃដំបូងបន្ទាប់ពីការរងរបួសដំបូងរបស់អ្នក ត្រូវបានចាត់ទុកថាជារយៈពេល "ការបង់ប្រាក់ដោយមិនមានការវិនិច្ឆ័យ ជាមុន" ។ នេះមានន័យថា ក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក អាចបង់ប្រាក់អត្ថប្រយោជន៍ជូនអ្នករហូតដល់ 180 ថ្ងៃដោយមិនបាច់ធ្វើសេចក្តីសម្រេចចុងក្រោយលើសំណុំរឿងរបស់អ្នក ។ **ការបង់ប្រាក់ជូនអ្នកអំឡុងពេលនេះ មិន មានន័យថាពួកគេបានទទួលយកការទទួលខុសត្រូវនោះឡើយ ។** អំឡុងរយៈពេលដំបូងនេះ ក្រុមហ៊ុនធានារ៉ាប់រង អាចបញ្ឈប់ ឬកាត់បន្ថយការបង់ប្រាក់របស់អ្នក ដោយការផ្តល់ជូនអ្នកនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សររយៈពេលប្រាំពីរថ្ងៃតាមរយៈ *សេចក្តីជូនដំណឹងអំពីការបញ្ឈប់ ឬការកែប្រែសំណងប្រចាំសប្តាហ៍របស់ក្រុមហ៊ុនធានារ៉ាប់រងអំឡុងរយៈពេលនៃការបង់ប្រាក់ដោយមិនមានការវិនិច្ឆ័យជាមុន (Insurer's Notification of Termination or Modification of Weekly Compensation During Payment-Without-Prejudice Period [ទម្រង់ 106]* ។ ក្រុមហ៊ុនធានារ៉ាប់រងត្រូវតែផ្តល់មូលហេតុសំរាប់ការចាត់វិធានការណ៍នេះ ។ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងបន្តបង់ប្រាក់ជូនអ្នកលើសរយៈពេលនេះ នៅក្នុងករណីភាគច្រើនបំផុតពួកគេនឹងត្រូវការការអនុញ្ញាតពីអ្នក ឬចៅក្រម ដើម្បីបញ្ឈប់ ឬកាត់បន្ថយអត្ថប្រយោជន៍របស់អ្នក ។ ប្រសិនបើអ្នកទទួលបាន

*ទម្រង់ 106* ហើយអ្នកទទួលបានសេចក្តី ជូនដំណឹងអំពីការបញ្ឈប់អត្ថប្រយោជន៍ សូមប្រាកដថាពិគ្រោះយោបល់ជាមួយមេធាវី ដើម្បីពិភាក្សាអំពីសិទ្ធិ និងការទទួលខុសត្រូវ របស់អ្នក។

ក្រុមហ៊ុនធានារ៉ាប់រងអាចស្នើសុំអ្នកឱ្យពន្យារយៈពេលនៃ "ការបង់ប្រាក់ដោយមិនមានការវិនិច្ឆ័យជាមុន" 180 ថ្ងៃដំបូងនោះរហូតដល់ មួយឆ្នាំ ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នកនៅលើ *កិច្ចព្រមព្រៀងពន្យារការបង់ប្រាក់ដោយមិនមានការវិនិច្ឆ័យ ជាមុនរយៈពេល 180 ថ្ងៃ (Agreement To Extend 180 Day Payment-Without-Prejudice Period (ទម្រង់ 105)* ។ DIA ត្រូវតែយល់ព្រមលើទម្រង់នេះ។ អ្នកត្រូវប្រាកដថា អ្នកដឹងច្បាស់ពីសិទ្ធិរបស់អ្នកទាំងអស់ មុនពេលផ្តល់ការ យល់ព្រមរបស់អ្នក ឬចុះហត្ថលេខាលើឯកសារផ្សេងទៀតណាមួយ។

## តើមានអ្វីកើតឡើងនៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបដិសេធបណ្តឹងទាមទាររបស់អ្នក?

ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងសម្រេចបដិសេធបណ្តឹងទាមទាររបស់អ្នក ពួកគេត្រូវតែផ្ញើរជូនអ្នកតាមរយៈប្រៃសណីយ៍អនុសិដ្ឋនូវ *សេចក្តីជូនដំណឹងអំពីការបដិសេធរបស់ក្រុមហ៊ុនធានារ៉ាប់រង (Insurer's Notification of Denial) [ទម្រង់ 104]* ដែលមាននូវមូលហេតុ សំរាប់ការបដិសេធ និងត្រូវតែជូនដំណឹងអ្នកនូវសិទ្ធិដាក់បណ្តឹងរបស់អ្នក។ ប្រសិនបើអ្នកមានចម្ងល់អំពីការបដិសេធ ឬការបង់ប្រាក់មិនគ្រប់នៅលើ ទម្រង់ទាំងនេះ សូមទាក់ទងអ្នកតំណាងផ្នែកបណ្តឹងទាមទាររបស់ក្រុមហ៊ុនធានារ៉ាប់រង។ លេខទូរស័ព្ទរបស់ពួកគេ នឹងត្រូវបានរាយបង្ហាញនៅលើ ទម្រង់។ ប្រសិនបើអ្នកបានជួលមេធាវី សូមឱ្យមេធាវីទូរស័ព្ទទៅអ្នកតំណាងផ្នែកបណ្តឹងទាមទារ ប្រាប់អំពីការបដិសេធរបស់អ្នក។ អ្នកតំណាងផ្នែក បណ្តឹងទាមទារ មិនអាចនិយាយជាមួយអ្នកផ្ទាល់អំពីការប្តឹងទាមទាររបស់អ្នក នៅពេលដែលអ្នកមានមេធាវីនោះឡើយ។

## អ្វីដែលអ្នកត្រូវធ្វើនៅពេលក្រុមហ៊ុនធានារ៉ាប់រងបដិសេធបណ្តឹងទាមទាររបស់អ្នក ឬអ្នកមិនបានទទួលអត្ថប្រយោជន៍ទាំងអស់ដែលអ្នកមានសិទ្ធិទទួល

ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងបដិសេធបណ្តឹងទាមទាររបស់អ្នក អ្នកមានសិទ្ធិដាក់បណ្តឹងទាមទារជាមួយ DIA ។ **ប្រសិនបើអ្នកចង់ដាក់បណ្តឹងទាមទារជាមួយ DIA សូមផ្តល់យោបល់យ៉ាងមុតមាំថា ត្រូវមានការតំណាងផ្នែកច្បាប់នៅចំណុចនៃដំណើរការនេះ។** បំពេញឱ្យបានពេញលេញ និង ត្រឹមត្រូវព្រមទាំងដាក់ជូន *បណ្តឹងទាមទាររបស់និយោជិក Employee's Claim] [ទម្រង់ 110]* ជូន DIA ដែលអ្នកអាចចូលប្រើបានពី ចំណុច "Forms and Publications" នៅតាមគេហទំព័ររបស់យើងខ្ញុំ [www.mass.gov/dia](http://www.mass.gov/dia) និងនៅការិយាល័យ DIA ណាមួយ។ សូមកុំផ្ញើរទម្រង់នេះទៅកាន់ DIA បើពុំនោះទេលុះត្រាតែអ្នកបានទទួល *សេចក្តីជូនដំណឹងអំពីការបដិសេធរបស់ក្រុមហ៊ុនធានារ៉ាប់រង (Insurer's Notification of Denial) [ទម្រង់ 104]* ឬវាមានរយៈពេល 30 ថ្ងៃ ឬច្រើនជាងនេះចាប់ពីកាលបរិច្ឆេទនៃការរងរបួស ឬជម្ងឺរបស់អ្នក ហើយអ្នកមិនបានទទួលដំណឹងពីក្រុមហ៊ុនធានារ៉ាប់រង។

- នៅពេលដាក់*ទម្រង់ 110* សូមប្រាកដថាភ្ជាប់សំណៅចម្លងនៃភស្តុតាងវេជ្ជសាស្ត្រ ដែលគាំទ្របណ្តឹងទាមទាររបស់អ្នកដែលរួមមាន វិក្ក័យប័ត្រវេជ្ជសាស្ត្រ និងរបាយការណ៍វេជ្ជសាស្ត្រ (សូមកុំភ្ជាប់ការឆ្លុះកាំរស្មីអ៊ិច MRI ។ល។) ដែលកត់ត្រាអំពីថាតើការរងរបួស ឬជម្ងឺពាក់ព័ន្ធនឹងការងាររបស់អ្នកយ៉ាងដូចម្តេច។ សូមដាក់ជូនកញ្ចប់បណ្តឹងទាមទារជូន DIA តាមអាសយដ្ឋានដែលបានព្រីននៅខាងលើ *ទម្រង់ 110* ។

- អ្នកត្រូវតែផ្ញើរ*ទម្រង់ 110* បំពេញរួចមួយច្បាប់ជូនក្រុមហ៊ុនធានារ៉ាប់រង។ យើងខ្ញុំសូមណែនាំឱ្យអ្នករក្សាទម្រង់នេះមួយច្បាប់សំរាប់ជាឯកសារផ្ទាល់ខ្លួនរបស់អ្នក។

- នៅពេលដែល DIA ទទួលបាន*ទម្រង់ 110* បំពេញរួចរបស់អ្នក អ្នកនឹងត្រូវបានកំណត់ពេលជួបសំរាប់ការសម្រុះសម្រួលអំឡុងពីរ សប្តាហ៍។ នេះនឹងចាប់ផ្តើមដំណើរការនៃជម្លោះ។ អ្នកនឹងត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងនៃការប្រជុំនេះ។

**សូមចំណាំ :** នៅពេលអ្នកមកកាន់ការិយាល័យ DIA ណាមួយសំរាប់ដំណើរការបណ្តឹងណាមួយ សូមប្រាកដថានាំមកជាមួយអ្នកនូវនូវការទំនាក់ទំនងណាមួយដែលក្រុមហ៊ុនធានារ៉ាប់រង ឬ DIA បានផ្ញើរជូនអ្នក ស្របជាមួយនឹងឯកសារពាក់ព័ន្ធផ្សេងទៀតណាមួយ ***ជាពិសេសសេចក្តីជូនដំណឹងអំពីដំណើរការបណ្តឹង (Notice of Proceeding) ដែលប្រាប់អ្នកឱ្យមកកាន់ DIA ។***

## ដំណើរការនៃជម្លោះ

### 1. ការសម្រុះសម្រួល

ដំណាក់កាលដំបូងនៃដំណើរការនៃជម្លោះ ត្រូវបានផ្តួចផ្តើមឡើងនៅពេលដែល DIA ទទួលបានទម្រង់ណាមួយក្នុងចំណោមទម្រង់ខាងក្រោម :

1. *បណ្ដឹងរបស់និយោជិក (Employee's Claim) [ទម្រង់ 110]* ដែលត្រូវបានដាក់ដោយនិយោជិកដែលរងរបួស ឬអ្នកពិគ្រោះយោបល់ផ្នែកច្បាប់របស់ពួកគេចំពោះក្រុមហ៊ុនធានារ៉ាប់រងសំណងនិយោជិក ។

2. *បណ្ដឹងរបស់ក្រុមហ៊ុនធានារ៉ាប់រងសំរាប់ការកែប្រែ ការបញ្ឈប់ ឬការសងវិញនូវសំណង (Insurer's Complaint for Modification, Discontinuance or Recoupment of Compensation) [ទម្រង់ 108]* ដែលត្រូវបានដាក់នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងស្នើសុំការអនុញ្ញាតបញ្ឈប់ ឬផ្លាស់ប្ដូរអត្ថប្រយោជន៍របស់អ្នក ។

បន្ទាប់ពីការទទួលបានទម្រង់ណាមួយនៃទម្រង់ទាំងនេះ ការប្រជុំក្រៅផ្លូវការមួយនឹងត្រូវបានកំណត់ពេលជួបជាស្វ័យប្រវត្តិរវាងអ្នក (អ្នកតំណាងស្របច្បាប់របស់អ្នក) មេធាវីរបស់ក្រុមហ៊ុនធានារ៉ាប់រង និងអ្នកសម្រុះសម្រួលពី DIA ។ ការប្រជុំនេះដែលត្រូវបានហៅថា "ការសម្រុះ សម្រួល" ជាធម្មតាកើតឡើងអំឡុង 12 ថ្ងៃធ្វើការបន្ទាប់ពីការដាក់ *ទម្រង់110* ឬ *ទម្រង់108* ។ នៅឯការសម្រុះសម្រួល កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីឈានទៅដល់ការព្រមព្រៀងដោយស្ម័គ្រចិត្តរវាងអ្នក និងក្រុមហ៊ុនធានារ៉ាប់រង ។ ប្រសិនបើការព្រមព្រៀងដោយស្ម័គ្រចិត្តមិនអាចសម្រេចបានទេ ស្ថានភាពនៃបណ្ដឹងទាមទាររបស់អ្នក នឹងរក្សាទុកដដែលដូចពីមុន ហើយសំណុំរឿងរបស់អ្នក អាចត្រូវបានបញ្ជូនទៅកាន់ចៅក្រមម្នាក់ក្នុងចំណោមចៅក្រមរបស់យើងខ្ញុំសំរាប់ការប្រជុំមួយ ។

## 2. ការប្រជុំ

ការប្រជុំគឺជាដំណើរការគតិយុត្តមិនផ្លូវការ នៅចំពោះមុខចៅក្រមរដ្ឋបាលវេណី ហើយជាធម្មតានឹងកើតឡើងរវាង 8 ទៅ 12 សប្ដាហ៍បន្ទាប់ពីកាលបរិច្ឆេទនៃការសម្រុះសម្រួល ។ ចៅក្រមសិក្សាអំពីសំណុំរឿងពីការបង្ហាញដោយភាគីទាំងពីរ និងការដាក់ជូនឯកសារដូចជា របាយការណ៍វេជ្ជសាស្ត្រ របាយការណ៍ប្រាក់កម្រៃ និងលិខិតបញ្ជាក់អះអាងពីសាក្សី ។ សាក្សីមិនត្រូវបានកោះហៅទេ ។ អ្នក ឬមេធាវីរបស់អ្នកបញ្ជាក់ជូនចៅក្រមពីអ្វីដែលសាក្សីនឹងនិយាយ ។

នៅឯការប្រជុំ អ្នកត្រូវបង្ហាញថា :

(A) អ្នកពិការ

(B) ការរងរបួស ឬជម្ងឺ គឺពាក់ព័ន្ធនឹងការងារ ហើយ

(C) វិក្កយប័ត្រវេជ្ជសាស្ត្រដែលមានបញ្ហាណាមួយ គឺសំរាប់ការព្យាបាលចាំបាច់ ។

បន្ទាប់ពីការប្រជុំ ចៅក្រមចេញសេចក្ដីបង្គាប់មួយ ដែលប្រាប់ឱ្យក្រុមហ៊ុនធានារ៉ាប់រងបង់អត្ថប្រយោជន៍របស់អ្នក ឬនិយាយថាពួកគេមិនត្រូវបានតម្រូវឱ្យបង់អត្ថប្រយោជន៍របស់អ្នក ។

សេចក្ដីបង្គាប់នៃការប្រជុំ អាចត្រូវបានប្ដឹងដោយភាគីណាមួយនៅលើ *បណ្ដឹងនៃដំណើរការការប្រជុំ (Appeal of a Conference Proceeding - ទម្រង់121)* ។ អ្នកមានពេលវេលា 14 ថ្ងៃដើម្បីប្ដឹងចាប់គិតពីកាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ។ **មាននូវការបង់ប្រាក់កម្រៃដើម្បីប្ដឹងចំពោះសេចក្ដីបង្គាប់នៃការប្រជុំ ប្រសិនបើបណ្ដឹងរបស់អ្នកផ្អែកទៅលើបញ្ហាវេជ្ជសាស្ត្រ ។** ការបង់ប្រាក់កម្រៃនេះបង់សំរាប់អ្នក ដើម្បីទទួលការវាយតម្លៃដោយគ្រូពេទ្យវេជ្ជសាស្ត្រមិនលំអៀង ។ ការបង់ប្រាក់កម្រៃនេះ អាចត្រូវបានបដិសេធប្រសិនបើអ្នកអាចបង្ហាញថាអ្នកមិនអាចលៃលកបង់ប្រាក់កម្រៃដោយការដាក់ជូន *លិខិតបញ្ជាក់អះអាងអំពីទុរគតភាព និងការស្នើសុំបដិសេធប្រាក់កម្រៃនៃសេកសិន 11A (2) (Affidavit of Indigence and Request for Waiver of Sec.11A (2)) [ទម្រង់136]* ។ ប្រសិនបើភាគីណាមួយប្ដឹងចំពោះ សេចក្ដីបង្គាប់នៃការប្រជុំ សវនាការផ្លូវការមួយចំពោះមុខចៅក្រមដូចគ្នា នឹងត្រូវបានកំណត់ពេលជួប ។

## 3. សវនាការ

**សវនាការ គឺជាដំណើរការគតិយុត្តិផ្លូវការមួយ ។** ជាធម្មតា វាត្រូវបានរៀបចំនៅចំពោះមុខចៅក្រមដដែល ដែលបានធ្វើជាប្រធាននៅឯការប្រជុំ ។ វិធានស្ដីពីភស្តុតាងរដ្ឋម៉ាស្សាឈូសិត (Massachusetts Rules of Evidence) នឹងអនុវត្ត ហើយការផ្ដល់ចម្លើយសាក្សីដែលបានស្បថ នឹងត្រូវបានធ្វើឡើង ។ សាក្សី ត្រូវបានកោះហៅ និងពិនិត្យទៅវិញទៅមកដោយភាគីជំទាស់ ។ ម៉ាស៊ីនថតសម្លេង នឹងថតក្នុងដំណើរការនេះ ។

ចៅក្រម នឹងធ្វើសេចក្តីសម្រេចក្នុងសវនាការ ដែលក្នុងនោះអ្នកនឹងត្រូវបានផ្តល់ជូនអត្ថប្រយោជន៍ ឬមិនត្រូវបានផ្តល់ជូន។ សេចក្តី សម្រេចនេះ អាចត្រូវបានប្តឹងទៅកាន់ក្រុមប្រឹក្សាពិនិត្យ (Reviewing Board) ដោយភាគីណាមួយនៅលើ *បណ្តឹងជូនក្រុមប្រឹក្សាពិនិត្យ (Appeal to Reviewing Board - ទម្រង់ 112)* ។ បណ្តឹងនេះ អាចត្រូវបានធ្វើឡើងតែប្រសិនបើភាគីតបតថា ចៅក្រមបានប្រព្រឹត្ត កំហុសនៃច្បាប់នៅក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន ឬនៅក្នុងអំឡុងពេលសវនាការ។ បណ្តឹងត្រូវតែបានទទួលយកក្នុងអំឡុង 30 ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់សវនាការ។ នឹងមានកម្រៃបណ្តឹងស្មើនឹង 30 ភាគរយនៃប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមរបស់រដ្ឋ (State Average Weekly Wage)[1] ដែលនឹងមាននៅពេលបណ្តឹង។ កម្រៃនេះអាចត្រូវបានបដិសេធ ដោយការដាក់ *លិខិតបញ្ជាក់អះអាងនៅក្នុងការគាំទ្រការស្នើសុំលិខិតបញ្ជាក់ការបដិសេធកម្រៃនៃការដាក់បណ្តឹងស្ថិតក្រោមសេកសិន 11C (Affidavit in Support of Request for Waiver of Filing Fee Under Sec.11C 0 - ទម្រង់ 112A)* ។

## 4. ក្រុមប្រឹក្សាពិនិត្យគ្រោះថ្នាក់ឧស្សាហកម្ម

ប្រសិនបើភាគីមួយ ឬពីរនៃបណ្តាភាគី ចង់ប្តឹងចំពោះសេចក្តីសម្រេចនៃសវនាការ បណ្តឹងនោះនឹងត្រូវបានធ្វើសវនាការ និងសម្រេចដោយក្រុមប្រឹក្សា ពិនិត្យ (Review Board) ។ ក្រុមប្រឹក្សានេះរួមមានសមាសភាពចៅក្រមរដ្ឋបាលប្បវេណីប្រាំមួយរូប ដែលបីនាក់ក្នុងចំណោមនោះ នឹងពិនិត្យមើល ឯកសារសវនាការ។ ពួកគេអាចស្នើសុំសេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរបន្ថែម ឬសេចក្តីសំអាងផ្ទាល់មាត់ពីបណ្តាភីគ។ ក្រុមប្រឹក្សាពិនិត្យ (Review Board) អាចកែប្រែ ឬរក្សាសេចក្តីសម្រេចរបស់ចៅក្រមរដ្ឋបាលប្បវេណី ឬអាចកំណត់ថាកិច្ចការបន្ថែមទៀតចាំបាច់ត្រូវធ្វើ ហើយបញ្ជូន (ផ្ញើរត្រឡប់) សំណុំរឿងទៅចៅក្រមរដ្ឋបាលប្បវេណីសំរាប់ការស្វែងរកបន្ថែមទៀត។ ភាគីនីមួយៗ អាចដាក់បណ្តឹងចំពោះសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាពិនិត្យ (Review Board) ទៅតុលាការឧទ្ធរណ៍ (Court of Appeals) ក្នុងអំឡុង 30 ថ្ងៃនៃសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាពិនិត្យ (Review Board) ។

## 5. បណ្តឹងបន្ថែមទៀត

ប្រសិនបើភាគីមួយ ឬពីរនៃបណ្តាភាគី ចង់ប្តឹងចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពិនិត្យ (Review Board) បណ្តឹងនឹងត្រូវបានធ្វើសវនាការ ដោយតុលាការឧទ្ធរណ៍រដ្ឋម៉ាស្សាឈូសិត (Massachusetts Court of Appeals) ។

# តើអត្ថប្រយោជន៍នៃសំណងនិយោជិកមានអ្វីខ្លះ?

## អត្ថប្រយោជន៍នៃអសមត្ថភាពទាំងស្រុងបណ្តោះអាសន្ន (សេកសិន 34)

### តើនរណាខ្លះមានលក្ខណៈសម្បត្តិទទួល?

អ្នកមានលក្ខណៈសម្បត្តិទទួល ប្រសិនបើការរងរបួស ឬជម្ងឺរបស់អ្នកទុកអ្នកឱ្យមិនអាចធ្វើការងារបាន - ដោយគិតទៅលើអាយុ ការ បណ្តុះបណ្តាល និងបទពិសោធន៍ - សំរាប់រយៈពេលប្រាំមួយថ្ងៃ ឬច្រើនជាងនេះពេញ ឬមិនពេញលេញ (ថ្ងៃទាំងនេះមិនចាំបាច់បន្តបន្ទាប់ គ្នាឡើយ) ។

### តើអត្ថប្រយោជន៍មានអ្វីខ្លះ?

អត្ថប្រយោជន៍របស់អ្នក នឹងមាន 60% នៃប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមដុល (មុនបង់ពន្ធ អត្ថប្រយោជន៍មុន) របស់អ្នក។[2] ដើម្បីកំណត់ពីសំណងរបស់អ្នក សរុបប្រាក់កម្រៃដុលសរុបរបស់អ្នក ដែលរួមទាំងប្រាក់លើសម៉ោង ប្រាក់រង្វាន់។ល។ សំរាប់រយៈពល 52 សប្តាហ៍មុនកាលបរិច្ឆេទនៃការរងរបួសរបស់អ្នក ហើយចែកប្រាក់សរុបនឹង 52 ដើម្បី គណនាប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមរបស់អ្នក។ (**ចំណាំ :** ប្រសិនបើអ្នកមានការងារធ្វើតែត្រឹមមួយផ្នែកនៃ 52 សប្តាហ៍ មុនការរង របួស ឬជម្ងឺ ចែកប្រាក់កម្រៃដុលសរុបនឹងចំនួន សប្តាហ៍នៃការងារនាឆ្នាំមុននោះ ដើម្បីកំណត់ប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមរបស់អ្នក។) គុណប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមរបស់អ្នក នឹង 60% (.60)

---

[1] គិតត្រឹមថ្ងៃទី 1 ខែ តុលា ឆ្នាំ 2010 ប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមរបស់រដ្ឋ (State Average Weekly Wage - SAWW) គឺ $1088.06 ហើយ ប្រាក់កម្រៃនៃបណ្តឹងគឺ $326.41 ។SAWW ត្រូវបានកែប្រែឡើងវិញជារៀងរាល់ឆ្នាំនៅថ្ងៃទី 1 ខែ តុលា។ អ្នកអាចស្វែងរកព័ត៌មានកែប្រែតាម www.mass.gov/dia និងចុចលើអាយខន Minimum/Maximum Compensation Rate ។

[2] និយមន័យពេញនៃប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យម (Average Weekly Wage) អាចរកបាននៅក្នុងច្បាប់ទូទៅរដ្ឋម៉ាស្សាឈូសិត (Massachusetts General Laws) ជំពូក 152 សេកសិន 1 ។

ដើម្បីរកសំណងប្រចាំសប្តាហ៍ប្រហាក់ប្រហែលរបស់អ្នក ដោយស្ថិតក្រោមសេកសិន 34 ។ កម្រិតអតិបរមាដែល អ្នកអាចទទួលបានគឺ ប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមរបស់រដ្ឋ (State's Average Weekly Wage - SAWW) [3] នៅពេល នៃការរងរបួសរបស់អ្នក ។

### សម្រាប់រយៈពេលប៉ុណ្ណា?

អ្នកអាចទទួលបានអត្ថប្រយោជន៍ទាំងនេះរហូតដល់ 156 សប្តាហ៍ (3 ឆ្នាំ) ។ សំណងចាប់ផ្តើមនៅថ្ងៃទីប្រាំមួយនៃអសមត្ថភាព ។ អ្នកនឹងមិនត្រូវបានផ្តល់សំណងសំរាប់ប្រាំថ្ងៃដំបូងនៃអសមត្ថភាពឡើយ លុះត្រាតែអ្នកពិការរយៈពល 21 ថ្ងៃ ឬច្រើនជាងនេះ ។ ថ្ងៃទាំងនេះមិនចាំបាច់ជាបន្តបន្ទាប់គ្នាឡើយ ។

## អត្ថប្រយោជន៍នៃអសមត្ថភាពមួយផ្នែក (សេកសិន 35)

### តើនរណាខ្លះមានលក្ខណៈសម្បត្តិទទួល?

អ្នកមានលក្ខណៈសម្បត្តិទទួល ប្រសិនបើអ្នកនៅតែធ្វើការ តែបាត់បង់ផ្នែកមួយនៃសមត្ថភាពរកប្រាក់កម្រៃរបស់អ្នក ដោយសារតែការ រងរបួស ឬជម្ងឺរបស់អ្នក ។ នេះអាចរួមមាន ការរងរបួសដែលបង្ខំឱ្យអ្នកផ្លាស់ប្តូរការងារទៅកាន់អត្រាប្រាក់កម្រៃទាបជាងមុន ឬការរងរបួសដែលតម្រូវឱ្យអ្នកធ្វើការតិចម៉ោងជាងមុន ។

### តើអត្ថប្រយោជន៍មានអ្វីខ្លះ?

សំណងអតិបរមាស្ថិតក្រោមសេកសិន 35 គឺរហូតដល់ 75% (.75) នៃអត្ថប្រយោជន៍បណ្តោះអាសន្នសរុបប្រចាំសប្តាហ៍របស់អ្នកដែល នឹងទទួលបាន ។ ឧទាហរណ៍ ប្រសិនបើអ្នកទទួលបាន $440 ក្នុងមួយសប្តាហ៍ជាអត្ថប្រយោជន៍បណ្តោះអាសន្នសរុប ទឹកប្រាក់ច្រើនបំផុត ដែលអ្នកទទួលបានប្រសិនបើអ្នកទទួលបានអត្ថប្រយោជន៍មួយផ្នែក នឹងមាន $330 ក្នុងមួយសប្តាហ៍ ។ ($440 x .75 = $330) ។

### សម្រាប់រយៈពេលប៉ុណ្ណា?

អ្នកអាចទទួលបានអត្ថប្រយោជន៍រហូតដល់ 260 សប្តាហ៍ (5 ឆ្នាំ) ។

## អត្ថប្រយោជន៍នៃភាពអសមត្ថភាពអចិន្ត្រៃយ៍ និងទាំងស្រុង (សេកសិន 34A)

### តើនរណាខ្លះមានលក្ខណៈសម្បត្តិទទួល?

អ្នកមានលក្ខណៈសម្បត្តិទទួល ប្រសិនបើអ្នកមិនអាចធ្វើការងារប្រភេទណាមួយនៃការងារទាំងស្រុង និងអចិន្ត្រៃយ៍ ដោយសារតែការរង របួស ឬជម្ងឺពាក់ព័ន្ធនឹងការងារ ។ អ្នកមិនចាំបាច់ទាល់អស់អត្ថប្រយោជន៍បណ្តោះអាសន្នរបស់អ្នក មុនពេលដាក់ពាក្យសុំអត្ថប្រយោជន៍ អចិន្ត្រៃយ៍នោះឡើយ ។

### តើអត្ថប្រយោជន៍មានអ្វីខ្លះ?

អ្នកនឹងទទួលបានពីរភាគបីនៃប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមរបស់អ្នក (ឬកម្រិតអប្បបរមា 20% នៃ SAWW) ដោយផ្អែកតាម 52 សប្តាហ៍មុនការរងរបួសរបស់អ្នក រហូតដល់កម្រិតអតិបរមារបស់ SAWW ។ អ្នកក៏មានសិទ្ធិទទួលបានការកែតម្រូវចំណាយនៃ ការរស់នៅប្រចាំឆ្នាំ (Cost-Of-Living Adjustments - COLA) ផងដែរ ។

### សម្រាប់រយៈពេលប៉ុណ្ណា?

អ្នកអាចទទួលបានអត្ថប្រយោជន៍រហូតទាល់តែអ្នកពិការ ។

---

[3] មកទល់ត្រឹមថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2010 ប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមរបស់រដ្ឋ (State Average Weekly Wage - SAWW) គឺ $1088.06 ។ អ្នកអាចស្វែងរកព័ត៌មានកែប្រែចុងក្រោយតាម www.mass.gov/dia និងចុចលើអាយខុន Minimum/Maximum Compensation Rate ។

## អត្ថប្រយោជន៍វេជ្ជសាស្ត្រ (សេកសិន 13 និងសេកសិន 30)

### តើនរណាខ្លះមានលក្ខណៈសម្បត្តិទទួល?

អ្នកមានលក្ខណៈសម្បត្តិទទួល ប្រសិនបើអ្នករងរបួស ឬជម្ងឺពាក់ព័ន្ធនឹងការងារ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រ។

### តើអត្ថប្រយោជន៍មានអ្វីខ្លះ?

អ្នកមានសិទ្ធិទទួលបានការថែទាំវេជ្ជសាស្ត្រគ្រប់គ្រាន់ និងសមរម្យ ដោយសារការរងរបួស ឬជម្ងឺ។ អ្នកក៏មានសិទ្ធិទទួលបានសំណងឱសថ តាមវេជ្ជបញ្ជា និងសំណងរយៈចម្ងាយសំរាប់ការធ្វើដំណើរទៅ និងមកពីការជួបពិនិត្យវេជ្ជសាស្ត្រសំរាប់ការរងរបួស ឬជម្ងឺពាក់ព័ន្ធនឹង ការងាររបស់អ្នកផងដែរ។ សំរាប់ការជួបពិនិត្យលើកដំបូងរបស់អ្នកជាមួយវេជ្ជបណ្ឌិត ឬមន្ទីរពេទ្យ និយោជករបស់អ្នកមានសិទ្ធិតែងតាំង អ្នកផ្តល់សេវាកម្មថែទាំសុខភាពនៅក្នុងការរៀបចំអ្នកផ្តល់សេវាកម្មតាមចំណូលចិត្តរបស់និយោជក។ បន្ទាប់ពីការព្យាបាលលើកដំបូង អ្នកមានសិទ្ធិជ្រើសរើសអ្នកផ្តល់សេវាកម្មថែទាំសុខភាពផ្ទាល់របស់អ្នក។ ក្រុមហ៊ុនធានារ៉ាប់រង មានសិទ្ធិបញ្ជូនអ្នកជាទៀងទាត់ទៅកាន់វេជ្ជបណ្ឌិតរបស់ខ្លួនសំរាប់ការវាយតម្លៃនៃអសមត្ថភាពរបស់អ្នក។

នៅពេលបណ្តឹងទាមទាររបស់អ្នក ត្រូវបានរាយការណ៍ជូនក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងត្រូវតែចេញជូនអ្នកនូវប័ណ្ណធានារ៉ាប់រងដែលមានលេខបណ្តឹងទាមទារ និងព័ត៌មានទំនាក់ទំនងនៅលើប័ណ្ណ។ ផ្តល់លេខបណ្តឹងទាមទារជូនវេជ្ជបណ្ឌិតរបស់អ្នក ហេតុនេះវេជ្ជបណ្ឌិតអាចចេញវិក្កយប័ត្រដោយផ្ទាល់ និងទទួលបានការយល់ព្រមជាមុនសំរាប់ការព្យាបាលការរងរបួស ឬជម្ងឺរបស់អ្នក។ ប្រសិនបើអ្នកមិនទទួលបានប័ណ្ណភ្លាមៗ បន្ទាប់ពីការរងរបួស ឬជម្ងឺរបស់អ្នកទេ សូមទាក់ទងក្រុមហ៊ុនធានារ៉ាប់រង និងទទួលបានលេខនេះ ដោយសារតែអ្នកផ្តល់សេវាកម្មវេជ្ជសាស្ត្រភាគច្រើនបំផុត នឹងមិនព្យាបាលអ្នកដោយមិនមានលេខបណ្តឹងទាមទារឡើយ។

### សម្រាប់រយៈពេលប៉ុណ្ណា?

អ្នកអាចទទួលបានអត្ថប្រយោជន៍រហូត ឱ្យតែសេវាកម្មវេជ្ជសាស្ត្រ និងសេវាកម្មនៅមន្ទីរពេទ្យត្រូវបានតម្រូវឱ្យមាន ដោយសារតែការរង របួស ឬជម្ងឺរបស់អ្នក។

## ការបាត់បង់មុខងារអចិន្ត្រៃយ៍ និងអត្ថប្រយោជន៍នៃការខូចរូបរាង (សេកសិន 36)

### តើនរណាខ្លះមានលក្ខណៈសម្បត្តិទទួល?

អ្នកមានលក្ខណៈសម្បត្តិទទួល ប្រសិនបើការរងរបួស ឬជម្ងឺពាក់ព័ន្ធនឹងការងារ បណ្តាលឱ្យមានការបាត់បង់មុខងាររាងកាយជាក់លាក់ អចិន្ត្រៃយ៍ ឬប្រសិនបើអ្នករងនូវស្លាកស្នាម ឬការខូចរូបរាងនៅលើមុខ ក ឬដៃ។

### តើអត្ថប្រយោជន៍មានអ្វីខ្លះ?

អ្នកទទួលបានការបង់ប្រាក់មួយដងសំរាប់ការខូចខាតរូបរាង និង/ឬការមានស្លាកស្នាម។ អត្ថប្រយោជន៍នេះ ត្រូវបានបង់បន្ថែមលើ អត្ថប្រយោជន៍ផ្សេងទៀត ឧទាហរណ៍ វិក្កយប័ត្រវេជ្ជសាស្ត្រ ប្រាក់កម្រៃដែលបាត់បង់ ។ល។ ទឹកប្រាក់ដែលបានបង់ ផ្អែកលើទីកន្លែង និង ភាពធ្ងន់ធ្ងរនៃការខូចខាតរូបរាង ឬមុខងារដែលបាត់បង់។

ប្រសិនបើអ្នករងរបួស ឬរងគ្រោះពីជម្ងឺមុនថ្ងៃទី 24 ខែ ធ្នូ ឆ្នាំ 1991 អ្នកមានអត្ថប្រយោជន៍ខុសគ្នាបន្តិច។ សូមទាក់ទងការិយាល័យ ព័ត៌មានសាធារណៈ (Public Information Office) របស់យើងខ្ញុំ ប្រសិនបើអ្នកមានចម្ងល់ណាមួយអំពីអត្ថប្រយោជន៍ទាំង នេះ។ ប្រសិនបើអ្នកមិនមានមេធាវី អ្នកអាចចង់ទាក់ទងផ្នែកសម្រុះសម្រួល (Conciliation Unit) របស់យើងខ្ញុំ ភ្លាមពេលដែល ក្រុមហ៊ុនធានារ៉ាប់រងបានផ្តល់សំណើសំរាប់ការមានស្លាកស្នាម និងការខូចខាតរូបរាង ហើយពិភាក្សាជាមួយអ្នកសម្រុះសម្រួល។ អ្នក សម្រុះសម្រួល អាចផ្តល់ជូនអ្នកនូវគំនិតអំពីថាតើការផ្តល់សំណើស្ថិតនៅក្នុងគោលការណ៍ណែនាំដែលបានបង្កើតដែរឬអត់។

### សម្រាប់រយៈពេលប៉ុណ្ណា?

អ្នកទទួលបានការបង់ប្រាក់មួយដងសំរាប់ការបាត់បង់មុខងាររាងកាយ ការខូចខាតរូបរាង និង/ឬការមានស្លាកស្នាមរបស់អ្នក។

## អត្ថប្រយោជន៍របស់អ្នកនៅមានជីវិត/អ្នកនៅក្នុងបន្ទុក (សេកសិន 31)

### តើនរណាខ្លះមានលក្ខណៈសម្បត្តិទទួល?

អ្នកមានលក្ខណៈសម្បត្តិទទួល ប្រសិនបើអ្នកគឺជាប្ដី-ប្រពន្ធ ឬកូនរបស់និយោជិកដែលបានស្លាប់ដោយសារការរងរបួស ឬជម្ងឺពាក់ព័ន្ធនឹង ការងារ។ កូន១មានលក្ខណៈសម្បត្តិទទួល តែប្រសិនបើពួកគេមានអាយុក្រោម 18 ឆ្នាំ គឺជាសិស្សពេញម៉ោង ឬមិនអាចធ្វើការងារបាន ដោយសារតែពិការភាពរាងកាយ ឬផ្លូវចិត្ត។

### តើអត្ថប្រយោជន៍មានអ្វីខ្លះ?

ប្ដី-ប្រពន្ធដែលនៅរស់ អាចទទួលបានអត្ថប្រយោជន៍ប្រចាំសប្ដាហ៍ស្មើនឹងពីរភាគបីនៃប្រាក់កម្រៃប្រចាំសប្ដាហ៍មធ្យមរបស់និយោជិកដែល បានស្លាប់ រហូតដល់កម្រិតអតិបរមានៃប្រាក់កម្រៃប្រចាំសប្ដាហ៍មធ្យមរបស់រដ្ឋ (State's Average Weekly Wage - SAWW) នៃរយៈពេលនៃការរងរបួស ឬមានជម្ងឺរបស់ពួកគេ។

ប្ដី-ប្រពន្ធដែលនៅរស់ ក្លាយជាមានលក្ខណៈសម្បត្តិទទួលសំរាប់ការកែតម្រូវចំណាយនៃការរស់នៅប្រចាំឆ្នាំ ពីរឆ្នាំបន្ទាប់ពីកាលបរិច្ឆេទ នៃការរងរបួស ឬជម្ងឺ។

ប្រសិនបើប្ដី-ប្រពន្ធនោះរៀបការម្ដងទៀត ទឹកប្រាក់ $60 ក្នុងមួយសប្ដាហ៍នឹងត្រូវបានបង់ជូនកូនដែលមានលក្ខណៈសម្បត្តិទទួល ម្នាក់ៗ។ ទឹកប្រាក់ប្រចាំសប្ដាហ៍សរុបដែលបានបង់ជូនកូនៗនៅក្នុងបន្ទុក មិនអាចលើសពីទឹកប្រាក់ដែលប្ដី-ប្រពន្ធបានកំពុងទទួលបាន ឡើយ។

### សម្រាប់រយៈពេលប៉ុណ្ណា?

ប្ដី-ប្រពន្ធដែលនៅរស់ អាចទទួលបានអត្ថប្រយោជន៍ទាំងនេះរហូត ឱ្យតែពួកគេនៅតែស្ថិតក្នុងបន្ទុក (ដូចដែលបានកំណត់ដោយចៅក្រម) និងមិនរៀបការម្ដងទៀត។

## ការចំណាយបញ្ចុះសព (សេកសិន 33)

ផ្នែកទី ៣៣ ក្នុងករណីទាំងអស់ក្រុមហ៊ុនធានារ៉ាប់រងត្រូវចំណាយថ្លៃដើមសមរម្យក្នុងការបញ្ចុះមិនលើសពី ៨ ដងនៃប្រាក់ឈ្នួលប្រចាំសប្តាហ៍ជាមធ្យមនៅក្នុងរដ្ឋម៉ាសាឈូសេតដូចដែលបានកំណត់ដោយអនុលោមតាមផ្នែករង ១កចុនៃផ្នែកទី ២៩ នៃជំពូក ១៥១ ។

## តើអត្ថប្រយោជន៍អាចត្រូវបានបញ្ចប់ ឬកាត់បន្ថយនៅពេលណា

អត្ថប្រយោជន៍របស់អ្នក អាចត្រូវបានបញ្ចប់ ឬកាត់បន្ថយដោយសារមូលហេតុជាច្រើន។ ឧទាហរណ៍នៃមូលហេតុទាំងនោះមាន :

- អត្ថប្រយោជន៍ត្រូវបានបង្គាប់ឱ្យបញ្ចប់ដោយចៅក្រមរដ្ឋបាលបូរណៈ (Administrative Judge) ក្រុមប្រឹក្សាពិនិត្យ (Reviewing Board) តុលាការជាន់ខ្ពស់ ឬមជ្ឈត្តករ។
- អ្នកបានវិលត្រឡប់ទៅធ្វើការងារវិញ។ ក្រុមហ៊ុនធានារ៉ាប់រង ត្រូវតែបន្តអត្ថប្រយោជន៍ប្រសិនបើអ្នកចាកចេញពីការងារម្ដងទៀត ដោយសារតែការរងរបួសដូចគ្នាអំឡុង 28 ថ្ងៃ បើពុំនោះទេលុះត្រាតែក្រុមហ៊ុនធានារ៉ាប់រងបានទទួលយក ឬត្រូវបានកំណត់ឱ្យនូវការ ទទួលខុសត្រូវសំរាប់ការរងរបួសរបស់អ្នក។
- ក្រុមហ៊ុនធានារ៉ាប់រងត្រូវបានផ្ដល់ជូននូវរបាយការណ៍វេជ្ជសាស្ត្រដោយវេជ្ជបណ្ឌិតព្យាបាលរបស់អ្នក ឬអ្នកពិនិត្យវេជ្ជសាស្ត្រមិនលំអៀង ដែលបង្ហាញថា អ្នកមានសមត្ថភាពវិលត្រឡប់មកធ្វើការងារវិញ **<u>ហើយ</u>**និយោជករបស់អ្នកបានរាយការណ៍ជា លាយលក្ខណ៍អក្សរថា តំណែងសមរម្យអាចមានសំរាប់អ្នកថា វេជ្ជបណ្ឌិតរបស់អ្នកបានយល់ព្រម។

- អ្នកត្រូវបានស្នើសុំឱ្យចូលរួមការវាយតម្លៃដោយមន្ត្រីពិនិត្យការស្តារនីតិសម្បទាវិជ្ជាជីវៈ (Vocational Rehabilitation Review Officer) របស់ DIA ហើយអ្នកបដិសេធមិនចូលរួម ឬអ្នកបដិសេធមិនសហការជាមួយនឹងការផ្តល់សេវាកម្មស្តារនីតិ សម្បទាវិជ្ជាជីវៈ ។
- អ្នកត្រូវបានស្នើសុំឱ្យទៅជួបវេជ្ជបណ្ឌិតរបស់ក្រុមហ៊ុនធានារ៉ាប់រងសំរាប់ការវាយតម្លៃ ហើយអ្នកខកខានចូលរួម ។
- អ្នកជាប់ពន្ធនាគារ បន្ទាប់ពីការចោទប្រកាន់ពីបទល្មើសមជ្ឈឹម ឬបទល្មើសកម្រិតធ្ងន់ ។

## ការទូទាត់ការបង់ប្រាក់សរុបផ្តាច់

ការទូទាត់ការបង់ប្រាក់សរុបផ្តាច់ គឺជាកិច្ចសន្យាស្របច្បាប់រវាងអ្នក ក្រុមហ៊ុនធានារ៉ាប់រង និងនៅក្នុងករណីមួយចំនួននិយោជិករបស់អ្នក ។ **ការទូទាត់ការបង់ប្រាក់សរុបផ្តាច់ គឺជាការបង់ប្រាក់តែម្តងដែលជាធម្មតាត្រូវបានធ្វើឡើងជំនួសឱ្យមូលប្បទានបត្រសំណងប្រចាំសប្តាហ៍របស់អ្នក ។** ការបង់ប្រាក់សរុបផ្តាច់ នឹងមិនប៉ះពាល់អត្ថប្រយោជន៍វេជ្ជសាស្ត្ររបស់អ្នកទេ ។ សូមប្រាកដថា នៅពេលទទួលយកការទូទាត់ថា អ្នកមានភាពច្បាស់លាស់អំពីសិទ្ធិរបស់អ្នក និងអ្វីដែលអ្នកអាចនឹងបោះបង់ចោល ដូចនេះអ្នកត្រូវតែពិចារណាដោយប្រុងប្រយ័ត្នថាតើការដោះស្រាយសំណុំរឿងរបស់ អ្នកគឺស្ថិតនៅក្នុងប្រយោជន៍ល្អបំផុតផ្ទាល់ខ្លួនរបស់អ្នកដែរឬអត់ ។ ជាថ្មីម្តងទៀត នេះគឺជាពេលវេលាសំខាន់ដើម្បីស្វែងរកការប្រឹក្សាផ្នែកច្បាប់ ។ ការបង់ប្រាក់សរុបផ្តាច់ មិនត្រូវបានផ្តល់ជូនដោយស្វ័យប្រវត្តិនោះទេ ។ អ្នក និងក្រុមហ៊ុនធានារ៉ាប់រង ត្រូវតែព្រមព្រៀងទទួលយក ហើយនៅក្នុងករណីភាគច្រើនបំផុត វាត្រូវតែបានយល់ព្រមដោយចៅក្រមរដ្ឋបាលបវេណី (Administrative Judge) នៅ DIA ។

នៅក្នុងការទទួលបានការទូទាត់ការបង់ប្រាក់សរុបផ្តាច់ អ្នកនៅតែអាចមានលក្ខណៈសម្បត្តិទទួលសេវាកម្មស្តារនីតិសម្បទាវិជ្ជាជីវៈដែលត្រូវបានបង់ដោយក្រុមហ៊ុនធានារ៉ាប់រង ។ សូមពិភាក្សាអំពីសិទ្ធិទាំងនេះជាមួយចៅក្រម ឬមេធាវីរបស់អ្នក មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាមួយ ។

សូមចូលមើលគេហទំព័ររបស់យើងខ្ញុំតាម **www.mass.gov/dia** ស្ថិតក្រោម “Department of Industrial Accident Publications” ដើម្បី ដោនឡូតខិតប័ណ្ណស្តីពីការបង់ប្រាក់សរុបផ្តាច់ ។

## សេវាកម្មស្តារនីតិសម្បទាវិជ្ជាជីវៈ

គោលបំណងនៃការស្តារនីតិសម្បទាវិជ្ជាជីវៈ (VR) គឺដើម្បីបញ្ជូនអ្នកទៅធ្វើការរកប្រាក់កម្រៃឱ្យបានប្រហាក់ប្រហែលបំផុតតាមដែលអាចដូចទៅនឹងអ្វីដែលអ្នករកប្រាក់កម្រៃបានមុនពេលការរងរបួស ឬជម្ងឺរបស់អ្នក ប្រសិនបើមិនបានច្រើនជាង ។ សេវាកម្ម VR រ៉ាប់រងលើរាល់សេវាកម្ម **មិនមែនវេជ្ជសាស្ត្រ**ទាំងអស់ដែលអ្នកអាចត្រូវការ ដើម្បីវិលត្រឡប់ទៅកាន់ការងារសមរម្យវិញ ។

ដោយផ្អែកតាមស្ថានភាពរបស់អ្នក សេវាកម្ម*អាច*រួមមាន : ការវាយតម្លៃសមត្ថភាពរបស់អ្នក ការធ្វើតេស្តិ៍ និងការបណ្តុះបណ្តាល វិជ្ជាជីវៈ ការពិគ្រោះយោបល់ ឬការណែនាំ ការកែប្រែកន្លែងធ្វើការ ការបណ្តុះបណ្តាលឡើងវិញផ្លូវការ និងការផ្តល់ជូនរកការងារ ។

ប្រសិនបើអ្នកទទួលបានសេចក្តីជូនដំណឹងដើម្បីជួបជាមួយមន្ត្រីម្នាក់ក្នុងចំណោមមន្ត្រីពិនិត្យ VR (VR Review Officers) របស់ យើងខ្ញុំ អ្នកត្រូវតែចូលរួមការប្រជុំនេះ ។ **ប្រសិនបើអ្នកខកខានមកកាន់ការប្រជុំនេះ អត្ថប្រយោជន៍របស់អ្នក អាចត្រូវបានបញ្ចប់ ។** ការប្រជុំនេះគឺដើម្បីកំណត់ថាតើអ្នកសក្តិសមសំរាប់សេវាកម្មដែលបានរៀបចំឡើងដើម្បីជួយដាក់អ្នកទៅកាន់ការងារដែរឬអត់ ។ ប្រសិនបើអ្នកបដិសេធមិនចូលរួមនៅក្នុងកម្មវិធីស្តារនីតិសម្បទាបន្ទាប់ពីត្រូវបានរកឃើញថាមានភាពសក្តិសម អត្ថប្រយោជន៍ប្រចាំសប្តាហ៍របស់អ្នកអាចត្រូវបានកាត់បន្ថយដោយក្រុមហ៊ុនធានារ៉ាប់រង ដោយមានសេចក្តីអនុញ្ញាតរបស់ DIA ។ សំរាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័ររបស់យើងខ្ញុំតាម **www.mass.gov/dia** ឬទូរស័ព្ទមកការិយាល័យព័ត៌មាន សាធារណៈ (Public Information Office) របស់យើងខ្ញុំសំរាប់ការទទួលបានខិតប័ណ្ណស្តីពី VR ។

## របៀបផ្ទៀងផ្ទាត់ការរ៉ាប់រងសំណងនិយោជិក

DIA ផ្តល់ជូននូវឧបករណ៍ "ភស្តុតាងអំពីការរ៉ាប់រង (Proof of Coverage -POC)" តាមគេហទំព័រតតគិតថ្លៃ ដែលអាចជួយផ្ទៀងផ្ទាត់ថាតើនិយោជកមានគោលនយោបាយអំពីសំណងនិយោជិកនាពេលបច្ចុប្បន្នដែរឬអត់ ។ ទោះបីជាឧបករណ៍ POC មិនត្រូវបានរៀបចំឡើងដើម្បីកំណត់រកការក្លែងបន្លំ វាអាចជួយនៅក្នុងការកំណត់ថាតើការក្លែងបន្លំកើតមានឡើងដែរឬអត់ ។ ដើម្បីចូល ប្រើប្រាស់ឧបករណ៍ POC សូមចូលទៅ **www.mass.gov/dia** និងចុចលើការភ្ជាប់ទៅកាន់ “Verify Workers’ Compensation Coverage” ។

ប្រសិនបើបន្ទាប់ពីការពិនិត្យមើលឧបករណ៍ POC អ្នកជឿជាក់ថា និយោជកមិនកំពុងផ្តល់ជូនការរ៉ាប់រងទេ សូមទាក់ទងការិយាល័យ ស៊ើបអង្កេត (Office of Investigations) របស់យើងខ្ញុំតាមលេខ 857-321-7313 ឬលេខ ឥតគិតថ្លៃតាមលេខ 1-877-MASSAFE (627-7233) ។ ឬបំពេញទម្រង់នៃការបញ្ជូនតាមគេហទំព័រ ។

## "សំណួរសួរញឹកញាប់"ដោយនិយោជិករងរបួស

សំរាប់ "សំណួរសួរញឹកញាប់" សូមចូលមើលគេហទំព័ររបស់យើងខ្ញុំតាម **www.mass.gov/dia** ។

## ព័ត៌មានសាធារណៈ

នីតិវិធីសំរាប់ការដាក់បណ្តឹងទាមទារអំពីសំណងនិយោជិក អាចមានលក្ខណៈច្របូកច្របល់ ។ ខិតប័ណ្ណនេះ អាចឆ្លើយនូវបណ្តាសំណួរមូលដ្ឋានបាន ។ ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរស័ព្ទទៅការិយាល័យណាមួយក្នុងចំណោមការិយាល័យប្រចាំតំបន់របស់យើងខ្ញុំ ឬទាក់ទងការិយាល័យ បូស្តុន (Boston office) របស់យើងខ្ញុំ ពីខាងក្នុងរដ្ឋម៉ាស្សាឈូសិត : 1-800-323-3249 លេខហៅបន្ត ។ ពីខាងក្រៅរដ្ឋ ម៉ាស្សាឈូសិត សូមទូរស័ព្ទទៅ 857-321-7470 ។ អ្នកក៏អាចចូលមើលគេហទំព័ររបស់យើងខ្ញុំតាម **www.mass.gov/dia** ។

TDD (សំរាប់អ្នកពិបាកស្តាប់តែប៉ុណ្ណោះ): 1-800-224-6196

## ការិយាល័យប្រចាំរបស់ DIA

**Boston**
Lafayette City Center
2 Avenue de Lafayette
Boston, MA 02114-2017
(617) 727-4900, (800) 323-3249

**Fall River**
1 Father DeValles Boulevard, 3rd Floor
Fall River, MA 02723
(508) 676-3406

**Lawrence**
354 Merrimack Street
Entrance C, Suite 230
Lawrence, MA 01843
(978) 683-6420

**Springfield**
436 Dwight Street
Springfield, MA 01103
(413) 784-1133

**Worcester**
Mercantile Center
100 Front St., Suite 310
Worcester, MA 01608
(508) 753-2072

**ខុមុំនវែលម៉ាស្សាឈូសិត (Commonwealth of Massachusetts)**
**ការិយាល័យប្រតិបត្តិការងារ និងអភិវឌ្ឍន៍ពលករ (Executive Office of Labor and Workforce Development)**
**ក្រសួងគ្រប់គ្រងគ្រោះថ្នាក់ឧស្សាហកម្ម (Department of Industrial Accidents)**

*គោលការណ៍ណែនាំអំពីសំណងនិយោជិករបស់អ្នក* ត្រូវបានបោះពុម្ពផ្សាយដោយក្រសួងគ្រប់គ្រងគ្រោះថ្នាក់ឧស្សាហកម្មរដ្ឋម៉ាស្សាឈូសិត (Massachusetts Department of Industrial Accidents) មានអាសយដ្ឋាននៅ
Lafayette City Center – 2 Avenue de Lafayette
Boston, MA 02111-1750
តុលា 2019 - ត្រូវបានបោះពុម្ពនៅលើក្រដាសច្នៃប្រើប្រាស់ឡើងវិញ